# ឯកសារទស្សនទាន

| | |
|---|---|
| *ឈ្មោះសកម្មភាព* | *កិច្ចប្រជុំលើកទី១ក្រុមបច្ចេកទេស* |
| *ក្របខណ្ឌលទ្ធផលនៃកម្មវិធី* UN-REDD | 2.3a: Establishment of a Benefit sharing<br>2.6a: Establishment of a Safeguards Technical Team<br>3.1a: Establishment of a Demonstration project Technical Team<br>4.1a: Technical Team of MRV Technical Teams |
| *កាលបរិច្ឆេទ និងទីកន្លែង* | *ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ នៅសណ្ឋាគារហ្គោលដឹនស៊ី ខេត្តព្រះសីហនុ* |
| *រយៈពេល* | *០១ ថ្ងៃ* |
| *ថវិកា* | 2.3a និង 2.6a |

## គោលបំណង

*កិច្ចប្រជុំមានគោលបំណងដូចខាងក្រោម:*

- *ជួយឲ្យសមាជិកក្រុមបច្ចេកទេសទាំងអស់យល់ដឹងពីតួនាទី ក្នុងការគាំទ្ររេដ+នៅកម្ពុជា។*
- *ជួយឲ្យសមាជិកក្រុមបច្ចេកទេស ទាំងអស់យល់ដឹងពីលក្ខខណ្ឌការងាររបស់ក្រុម ដែលពាក់ព័ន្ធនឹងប្រតិទិនការងាររបស់ក្រុមការងាររេដ+កម្ពុជា។*
- *ធ្វើបច្ចុប្បន្នភាពពីវឌ្ឍនភាព និងស្ថានភាពការងាររេដ+នៅកម្ពុជា និងណែនាំនូវប្រធានបទពាក់ព័ន្ធ។*
- *ជ្រើសរើសអ្នកដឹកនាំក្រុមនីមួយៗ ដើម្បីសុំការអនុម័តពីក្រុមការងាររេដ+កម្ពុជា។*

## យុត្តិកម្ម

*អនុត្តតាមការសម្រេចចិត្តរបស់ក្រុមការងាររេដ+កម្ពុជា ក្នុងការបង្កើត និងអនុម័តលក្ខខណ្ឌការងារក្រុមបច្ចេកទេស ទាំង៤ក្រុម ក្រសួងស្ថាប័នពាក់ព័ន្ធ បានចាត់បញ្ជូនមន្ត្រី មកចូលរួមជាសមាជិកក្រុម បច្ចេកទេស។ ស្របពេលជាមួយគ្នានេះក្រុមប្រឹក្សាយោបល់ក៏បានចាត់បញ្ជូនសមាជិកខ្លួនមកចូលរួមផងដែរ។*

*ក្រុមបច្ចេកទេស ទាំង៤ក្រុម នឹងមានតួនាទីសំខាន់ ក្នុងការផ្តល់អនុសាសន៍បច្ចេកទេស សម្រាប់ការអនុវត្តរេដ+នៅកម្ពុជា និងបំពេញការងារនៅក្រោមការណែនាំរបស់ក្រុមការងាររេដ+កម្ពុជា ដែលគាំទ្រដោយលេខាធិការដ្ឋានរេដ+កម្ពុជា។*

*ក្រុមបច្ចេកទេស ទាំង៤ មានការងារគ្របដណ្តប់លើប្រធានបទៈ ១)ប្រព័ន្ធធានាសុវត្ថិភាព ២)ការចែករំលែកផលប្រយោជន៍ ៣)ការសាកល្បងគម្រោងគំរូ ៤)ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ។ ក្រុមនីមួយៗមានគោលបំណង របៀបរបបបំពេញការងារ និងការទទួលខុសត្រូវដូចមានពណ៌នាពីនៅក្នុងលក្ខខណ្ឌការងារ។*

**វិធីសាស្ត្រ**

*ផ្នែកទី១នៃកិច្ចប្រជុំ មានការណែនាំពីវេជ+ និងការត្រៀមលក្ខណៈវេជ+នៅកម្ពុជា តួនាទី និងលក្ខខណ្ឌការងារ របស់ក្រុមបច្ចេកទេស ទាំង៤ក្រុម។*

*ផ្នែកទី២នៃកិច្ចប្រជុំ មានការប្រជុំលើកទី១តាមក្រុមនីមួយៗ ដែលគ្រប់ក្រុមមានការណែនាំពីប្រធានបទ និងការព្រមព្រៀងលើផែនការការងារសម្រាប់បណ្តា៦ខខាងមុខ និងការជ្រើសរើសប្រធានក្រុមបច្ចេកទេស។*

**លទ្ធផល**

*យើងមានការរំពឹងទុកថា បន្ទាប់ពីបានរៀបចំកិច្ចប្រជុំក្រុមបច្ចេកទេស សមាជិកក្រុមបច្ចេកទេស ទាំង៤ក្រុម នឹងមានការយល់ដឹង ពីតួនាទី និងកិច្ចការដែលក្រុមបច្ចេកទេសត្រូវបំពេញ និងព្រមព្រៀងតាម ជំហានការងារបន្ទាប់ពីនេះ។ យោងតាមលក្ខខណ្ឌការងារ ក្រុមបច្ចេកទេសនឹងមានការប្រជុំប្រចាំខែ។*